គណបក្ស សម រង្ស៊ី
SAM RAINSY PARTY
PARTI SAM RAINSY
សីលធម៌ សច្ចធម៌ យុត្តិធម៌

# បទបញ្ជា

# ស្តីពី

# ការរៀបចំ និង ការប្រព្រឹត្តទៅ

# នៃរចនាសម្ព័ន្ធគណបក្សមូលដ្ឋាន និង ខេត្ត-ក្រុង

## ជំពូក ១
## រចនាសម្ព័ន្ធគណបក្សមូលដ្ឋាន

**ប្រការ ១ :** រចនាសម្ព័ន្ធគណបក្សមូលដ្ឋាន ត្រូវបានបង្កើត និងរៀបចំឡើងដោយសមាជិកគណបក្សនៅមូលដ្ឋាន ។ រចនាសម្ព័ន្ធគណបក្សមូលដ្ឋានមាន :

- ក្រុមប្រឹក្សាគណបក្សភូមិ
- ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់
- ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ។

### ផ្នែកទី ១
### ក្រុមប្រឹក្សាគណបក្សភូមិ

**ប្រការ ២ :** ក្រុមប្រឹក្សាគណបក្សភូមិមានសមាជិកយ៉ាងតិចចំនួន៥រូប និងយ៉ាងច្រើនចំនួន១០រូបនៅក្នុងអាណត្តិទី១ ។ សមាជិកក្រុមប្រឹក្សាគណបក្សភូមិ ជ្រើសតាំងដោយសមាជិកគណបក្សនៅក្នុងភូមិ តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសម្លេងប្រៀប



ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphqpp@forum.org.kh, cabinet@samrainsyparty.org

ផ្អែកតាមបញ្ជីសមាជិកគណបក្សនៅក្នុងភូមិ ។ រៀងរាល់រយៈពេល៣ឆ្នាំ សមាជិកគណបក្សនៅក្នុងភូមិនីមួយៗ អាចជួបប្រជុំដើម្បីបោះឆ្នោតដកតួនាទីសមាសភាពក្រុមប្រឹក្សាគណបក្សភូមិ ឬជ្រើសតាំងបន្ថែមសមាជិកក្រុមប្រឹក្សាគណបក្សភូមិ ក្នុងករណីដែលចំនួនសមាជិកគណបក្សនៅក្នុងភូមិនីមួយៗកើនឡើង យោងតាមសំណើរបស់ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ។ ចំនួនសមាជិកក្រុមប្រឹក្សាគណបក្សភូមិដែលត្រូវជ្រើសតាំងបន្ថែមសំរាប់ភូមិនីមួយៗ មិនត្រូវមានចំនួនលើសពី៥រូបឡើយ ។ ក្នុងករណីពិសេស បើមានមតិមួយភាគបីនៃចំនួនសមាជិកគណបក្សនៅក្នុងភូមិ ស្នើសុំដកសេចក្តីទុកចិត្តប្រធាន ឬអនុប្រធាន ឬសមាជិកក្រុមប្រឹក្សាគណបក្សភូមិ ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី មានភារកិច្ចធ្វើការស៊ើបអង្កេត ហើយអាចកោះប្រជុំសមាជិកគណបក្សនៅក្នុងភូមិ ដើម្បីបោះឆ្នោតសំដែងការទុកចិត្តប្រធាន ឬអនុប្រធាន ឬសមាជិកក្រុមប្រឹក្សាគណបក្សភូមិ តាមនីតិវិធីដែលបានកំណត់នៅក្នុងបទបញ្ជានេះ ។

**ប្រការ ៣ :** ប្រជាពលរដ្ឋខ្មែររស់នៅក្នុងភូមិនីមួយៗ ដែលបានចូលជាសមាជិកគណបក្សជាផ្លូវការ (មានប័ណ្ណសមាជិក ឬបានដាក់ពាក្យសុំចូលជាសមាជិក) មានសិទ្ធិឈរឈ្មោះជាបេក្ខជននៃសមាជិកក្រុមប្រឹក្សាគណបក្សភូមិ និងមានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាគណបក្សភូមិ ។

**ប្រការ ៤ :** ប្រធាន និងអនុប្រធានក្រុមប្រឹក្សាគណបក្សភូមិ ត្រូវបានជ្រើសរើសចេញពីបញ្ជីសមាជិកក្រុមប្រឹក្សាគណបក្សភូមិ ដោយអ្នកដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេ ជាប្រធាន ហើយអ្នកដែលបានទទួលសម្លេងឆ្នោតបន្តបន្ទាប់ ជាអនុប្រធាន និងជាសមាជិក ។ ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាគណបក្សភូមិ ទទួលស្គាល់ដោយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ។

**ប្រការ ៥ :** ក្នុងករណីភូមិណាដែលការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណបក្សភូមិ មិនអាចប្រព្រឹត្តទៅបាន ដោយមិនទាន់មានសមាជិកគណបក្ស ឬមានសមាជិកតិចជាង៥នាក់ ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ដោយសហការណ៍ជាមួយថ្នាក់ដឹកនាំគណបក្សថ្នាក់មូលដ្ឋាន និងប្រធានក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌ រៀបចំការតែងតាំងជាបណ្តោះអាសន្ននូវក្រុមប្រឹក្សាគណបក្សភូមិនោះ រយៈពេល៦ខែម្តង ដើម្បីធានាដំណើរការនៃការប្រព្រឹត្តទៅរបស់គណបក្សភូមិ រហូតដល់ការបោះឆ្នោតអាចប្រព្រឹត្តទៅបាន ។

**ប្រការ ៦ :** ក្រុមប្រឹក្សាគណបក្សភូមិ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ពន្យល់ និងផ្សព្វផ្សាយអំពីគោលនយោបាយ កម្មវិធីនយោបាយ និងសារនយោបាយរបស់គណបក្សអោយបានទូលំទូលាយ ដល់ប្រជាពលរដ្ឋក្នុងភូមិ

- សិក្សា ស្វែងយល់អំពីបញ្ហាកង្វល់របស់ប្រជាពលរដ្ឋនៅក្នុងភូមិ ដើម្បីជួយធ្វើអន្តរាគមន៍ដោះស្រាយ
- ពង្រីក និងពង្រឹងបណ្តាញគណបក្សនៅក្នុងភូមិឲ្យបានរឹងមាំ
- ក្តាប់ស្ថិតិប្រជាពលរដ្ឋនៅក្នុងភូមិឲ្យបានច្បាស់លាស់
- ប្រមូលការគាំទ្រពីប្រជាពលរដ្ឋ និងជំរុញប្រជាពលរដ្ឋឲ្យចូលរួមក្នុងសកម្មភាពគណបក្ស
- រៀបចំផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សាគណបក្សភូមិ
- ចូលរួមបោះឆ្នោតជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។

**ប្រការ ៧ :** ប្រធានក្រុមប្រឹក្សាគណបក្សភូមិមានភារកិច្ចដូចតទៅ :

- ធានាដំណើរការនៃក្រុមប្រឹក្សាគណបក្សភូមិ ឲ្យស្របតាមគោលការណ៍របស់គណបក្ស
- កោះប្រជុំ និងដឹកនាំអង្គប្រជុំនៃក្រុមប្រឹក្សាគណបក្សភូមិ
- អនុវត្តផែនការដែលគណបក្សប្រគល់ជូន
- ធ្វើសេចក្តីរាយការណ៍ស្តីអំពីសកម្មភាពការងារគណបក្សនៅក្នុងភូមិ និងលើកសំណូមពរផ្សេងៗ ជូនក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ឬថ្នាក់ដឹកនាំគណបក្ស ។

អនុប្រធានក្រុមប្រឹក្សាគណបក្សភូមិ ជួយកិច្ចការប្រធាន និងទទួលភារកិច្ចតាមការកំណត់របស់ប្រធាន ហើយដឹកនាំការងារជំនួសប្រធានក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ។

## ផ្នែកទី ២
## ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់

**ប្រការ ៨ :** ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់នីមួយៗ មានសមាជិកយ៉ាងតិចចំនួន១០រូប និងយ៉ាងច្រើនចំនួន២២រូប ដោយផ្អែកទៅតាមចំនួនប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ-សង្កាត់នីមួយៗ សំរាប់អាណត្តិទី១នេះ ។ សមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សភូមិទាំងឡាយនៅក្នុងឃុំ-សង្កាត់សាមី តាមរយៈការបោះឆ្នោតសម្ងាត់ និងដោយមតិភាគច្រើនប្រៀប ។ រៀងរាល់ឆ្នាំ សមាជិកក្រុមប្រឹក្សាគណបក្សភូមិទាំងឡាយ នៅក្នុងឃុំ-សង្កាត់សាមី អាចជួបប្រជុំ ដើម្បីធ្វើការបោះឆ្នោតដកតួនាទី ឬជ្រើសតាំងបន្ថែមសមាជិកក្រុមប្រឹក្សាគណបក្ស

ឃុំ-សង្កាត់ ក្នុងករណីដែលចំនួនសមាជិកក្រុមប្រឹក្សាគណបក្សភូមិ នៅក្នុងឃុំ-សង្កាត់សាមីកើនឡើង យោងតាមសំណើរបស់ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ។ ចំនួនសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ដែលត្រូវជ្រើសតាំងបន្ថែមសំរាប់ឃុំ-សង្កាត់នីមួយៗ មិនត្រូវមានចំនួនលើសពី៥រូបឡើយ ។ សមាជិកក្រុមប្រឹក្សាគណបក្សភូមិ និងសមាជិកគណបក្សរស់នៅក្នុងឃុំ-សង្កាត់សាមី ដែលបានចូលជាសមាជិកគណបក្សរយៈពេលយ៉ាងតិច៦ខែ មានសិទ្ធិដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជន នៃសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ។ ទំរង់បែបបទនៃពាក្យសុំឈរឈ្មោះ កំណត់ដោយអគ្គលេខាធិការគណបក្ស ។

**ប្រការ ៩ :** ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ បង្កើតគណៈកម្មការអចិន្ត្រៃយ៍ ដើម្បីដឹកនាំ ចាត់ចែង និងអនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្សឃុំ-សង្កាត់សាមី ។ គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ មានប្រធាន អនុប្រធាន លេខាធិការ និងហេរញ្ញិក ។

**ប្រការ ១០ :** ប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់នីមួយៗ ត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់សាមី តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសម្លេងភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ទាំងអស់ សំរាប់អាណត្តិ៣ឆ្នាំ ។ អាណត្តិរបស់ប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ត្រូវបញ្ចប់នៅពេលប្រធានថ្មីមកជំនួស ។

អនុប្រធាន លេខាធិការ និងហេរញ្ញិក នៃក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ត្រូវបានជ្រើសរើសដោយប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ដែលមានអាណត្តិត្រូវចប់ជាមួយនឹងអាណត្តិរបស់ប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ។

**ប្រការ ១១ :** ប្រធាន អនុប្រធាន លេខាធិការ ហេរញ្ញិក និងសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ទទួលស្គាល់ដោយអគ្គលេខាធិការគណបក្ស តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ។

**ប្រការ ១២ :** មតិមួយភាគបីនៃចំនួនសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ មានសិទ្ធិធ្វើញត្តិមកគណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដើម្បីសុំដកសេចក្តីទុកចិត្តពីប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ។

គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង មានភារកិច្ចធ្វើការស៊ើបអង្កេតលើញត្តិនេះ ។ បើញត្តិនេះឥតមានក្លែងបន្លំ ហើយមានមូលដ្ឋាន និងមូលហេតុច្បាស់លាស់ គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដោយមានការយល់ព្រមពីអគ្គលេខាធិការគណបក្ស រៀបចំការបោះឆ្នោតសម្ងាត់ដកការទុកចិត្តចំពោះប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ តាមនីតិវិធីដែលបានកំណត់នៅក្នុងបទបញ្ញានេះ ។

**ប្រការ ១៣ :** ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ មានតួនាទី និងភារកិច្ច ដូចតទៅ :

- អនុវត្តទិសដៅ និងភារកិច្ចដែលគណបក្សប្រគល់ជូន
- ធានាការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់
- ពង្រីក និងពង្រឹងបណ្តាញគណបក្សនៅក្នុងភូមិ ឃុំ-សង្កាត់សាមី ឲ្យបានរឹងមាំ
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយនៅក្នុងមូលដ្ឋានរបស់ខ្លួន នូវគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសំរេច និងសេចក្តីណែនាំនានារបស់គណបក្ស
- តាមដាន ប្រមូល និងផ្តល់ពត៏មានដែលទាក់ទងនឹងផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន មកថ្នាក់ដឹកនាំគណបក្ស
- តាមដាន ត្រួតពិនិត្យ និងវាយតំលៃលើរាល់ការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាគណបក្សភូមិ និងសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់សាមី
- ជំរុញការអនុវត្តន៍ផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សាគណបក្សភូមិ
- ផ្សព្វផ្សាយផែនការសកម្មភាពការងាររបស់គណបក្ស និងសភាពការណ៍ផ្សេងៗដល់ក្រុមប្រឹក្សាគណបក្សភូមិ និងសកម្មជនគណបក្ស
- កំណត់ប្រាក់ភាគទានសំរាប់ឲ្យសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ បង់ប្រចាំខែ
- ចូលរួមបោះឆ្នោតជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។

**ប្រការ ១៤ :** គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ អាចបង្កើតក្រុមការងារផ្សេងៗដើម្បីជាជំនួយ ដូចជា ក្រុមការងារបណ្តាញ ក្រុមការងារពត៏មាន ឃោសនា និងផ្សព្វផ្សាយ ។ល។

**ប្រការ ១៥ :** ប្រធ ានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ មានភារកិច្ច និងកាតព្វកិច្ចដូចតទៅ :

- ធានាដំណើរការនៃក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ឲ្យស្របតាមគោលការណ៍របស់គណបក្ស
- កោះប្រជុំ និងដឹកនាំអង្គប្រជុំនៃក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់
- អនុវត្តផែនការដែលគណបក្សប្រគល់ជូន
- ជួយរៀបចំ និងទ្រទ្រង់ដំណើរការនៃចលនាយុវជនជាតិខ្មែរ និងចលនាស្ត្រីជាតិខ្មែរនៅក្នុងឃុំ-សង្កាត់សាមី
- ធ្វើរបាយការណ៍ស្តីអំពីសកម្មភាពការងារគណបក្សនៅក្នុងឃុំ-សង្កាត់ និងលើកសំណូមពរផ្សេងៗ ជូនក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ និងថ្នាក់ដឹកនាំគណបក្ស

-ចូលរួមបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រ សំរាប់មណ្ឌលខេត្ត-ក្រុងសាមី តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

**ប្រការ ១៦ :** អនុប្រធាន លេខាធិការ និងហេរញ្ញិកនៃក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ជួយកិច្ចការប្រធាន និងទទួលភារកិច្ចតាមការកំណត់របស់ប្រធាន ។ អនុប្រធានមួយរូបដឹកនាំការងារជំនួសប្រធានតាមការប្រគល់សិទ្ធិក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ។

**ប្រការ ១៧ :** ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ត្រូវជួបប្រជុំគ្នាយ៉ាងតិចមួយខែម្តង ដោយមានការចូលរួមពីប្រធានក្រុមប្រឹក្សាគណបក្សភូមិ ក្នុងឃុំ-សង្កាត់សាមី ដើម្បីពិនិត្យវាយតម្លៃសកម្មភាពការងារនៃក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងស្ថានការណ៍ទូទៅនៅក្នុងឃុំ-សង្កាត់ និងកំណត់ផែនការការងារសំរាប់ពេលខាងមុខ ។ ក្នុងករណីពិសេស ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់អាចប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើមួយភាគបីនៃសមាជិករបស់ខ្លួន ។ ការប្រជុំក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ឬអនុប្រធាន តាមការប្រគល់សិទ្ធិពីប្រធាន ។

## ផ្នែកទី ៣
## ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ

**ប្រការ ១៨ :** ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌនីមួយៗ មានសមាជិកយ៉ាងច្រើនចំនួន ២៥ រូប សំរាប់អាណត្តិទី១នេះ ។ សមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ទាំងឡាយ នៅក្នុងស្រុក-ខណ្ឌសាមី តាមរយៈការបោះឆ្នោតសម្ងាត់ និងដោយមតិភាគច្រើនប្រៀប ។ រៀងរាល់រយៈពេល៣ឆ្នាំ សមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ទាំងឡាយនៅក្នុងស្រុក-ខណ្ឌសាមី អាចជួបប្រជុំដើម្បីដកតួនាទី ឬជ្រើសតាំងបន្ថែមសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់នៅក្នុងស្រុក-ខណ្ឌសាមីកើនឡើង យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង បន្ទាប់ពីមានការពិភាក្សាជាមួយអគ្គលេខាធិការគណបក្ស ។ ចំនួនសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ដែលត្រូវជ្រើសតាំងបន្ថែមម្តងៗ មិនត្រូវមានចំនួនលើសពី៥រូបឡើយ ។ សមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងសមាជិកគណបក្សរស់នៅក្នុងស្រុក-ខណ្ឌសាមី ដែលបានចូលជាសមាជិកគណបក្សរយៈពេលយ៉ាងតិច១ឆ្នាំ មានសិទ្ធិដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជន នៃសមាជិកក្រុមប្រឹក្សា

គណបក្សស្រុក-ខណ្ឌ ។ ទំរង់បែបបទនៃពាក្យសុំឈរឈ្មោះ កំណត់ដោយអគ្គលេខាធិការគណបក្ស ។

**ប្រការ ១៩ :** ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ បង្កើតគណៈកម្មការអចិន្ត្រៃយ៍ ដើម្បីដឹកនាំចាត់ចែង និងអនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្សស្រុក-ខណ្ឌ ។ គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌមាន ប្រធាន អនុប្រធាន លេខាធិការ និងហេរញ្ញិក ។

**ប្រការ ២០ :** ប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ត្រូវបានជ្រើសតាំងដោយសមាជិកក្រុម-ប្រឹក្សាគណបក្សស្រុក-ខណ្ឌ តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសម្លេងភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងអស់ សំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិរបស់ប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ត្រូវបញ្ចប់នៅពេលប្រធានថ្មីមកជំនួស ។

អនុប្រធាន លេខាធិការ និងហេរញ្ញិក នៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ត្រូវបានជ្រើសរើសដោយប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ដែលមានអាណត្តិត្រូវចប់ជាមួយនឹងអាណត្តិរបស់ប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ។

**ប្រការ ២១ :** ប្រធាន អនុប្រធាន លេខាធិការ ហេរញ្ញិក និងសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ទទួលស្គាល់ដោយអគ្គលេខាធិការគណបក្ស តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ។

**ប្រការ ២២ :** មតិមួយភាគបីនៃចំនួនសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ មានសិទ្ធិធ្វើញត្តិមកគណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដើម្បីសុំដកសេចក្ដីទុកចិត្តពីប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ។

គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង មានភារកិច្ចធ្វើការស៊ើបអង្កេតលើញត្តិនេះ ។ បើញត្តិនេះឥតមានក្លែងបន្លំ ហើយមានមូលដ្ឋាន និងមូលហេតុច្បាស់លាស់ គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដោយមានការយល់ព្រមពីអគ្គលេខាធិការគណបក្ស រៀបចំការបោះឆ្នោតសម្ដែងការទុកចិត្តចំពោះប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ តាមនីតិវិធីដែលបានកំណត់នៅក្នុងបទបញ្ជានេះ ។

**ប្រការ ២៣ :** ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ មានតួនាទី និងភារកិច្ច ដូចតទៅ :

- អនុវត្តទិសដៅ និងភារកិច្ចដែលគណបក្សប្រគល់ជូន
- ធានាការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ
- ពង្រីក និងពង្រឹងបណ្ដាញគណបក្សតាមបណ្ដាឃុំ-សង្កាត់ ក្នុងស្រុក-ខណ្ឌ សាមីឲ្យបានរឹងមាំ

- ផ្សព្វផ្សាយឲ្យបានទូលំទូលាយនៅក្នុងមូលដ្ឋានរបស់ខ្លួន នូវគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសំរេច និងសេចក្តីណែនាំនានារបស់គណបក្ស
- តាមដាន ប្រមូល និងផ្តល់ពត៌មានដែលទាក់ទងនឹងផលប្រយោជន៏ជាតិ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន មកថ្នាក់ដឹកនាំគណបក្ស
- សហការជាមួយក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌ ដើម្បីធានាឲ្យការងារគណបក្សនៅក្នុងស្រុក-ខណ្ឌ មានការរីកចំរើន និងទទួលបានជោគជ័យនៅពេលបោះឆ្នោត
- កំណត់ប្រាក់ភាគទាន សំរាប់ឲ្យសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ បង់ប្រចាំខែ
- ជួយរៀបចំ និងទ្រទ្រង់ដំណើរការនៃចលនាយុវជនជាតិខ្មែរ និងចលនាស្ត្រីជាតិខ្មែរនៅក្នុងស្រុក-ខណ្ឌសាមី
- លើកសំណូមពរសុំអន្តរាគមន៍ពីថ្នាក់ដឹកនាំគណបក្ស ដើម្បីជួយណែនាំអំពីរបៀបរបបធ្វើការងារ ឲ្យមានប្រសិទ្ធភាព
- តាមដាន និងត្រួតពិនិត្យសកម្មភាពការងាររបស់ក្រុមប្រឹក្សាគណបក្សភូមិ ឃុំ-សង្កាត់ និងវាយតំលៃលើរាល់ការអនុវត្តន៏ការងាររបស់ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌសាមី
- ផ្សព្វផ្សាយផែនការសកម្មភាពការងាររបស់គណបក្ស និងសភាពការណ៏ផ្សេងៗដល់ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ឲ្យបានទាន់ពេលវេលា
- ចូលរួមបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រ ក្នុងមណ្ឌលខេត្ត-ក្រុងសាមី តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៏គណបក្ស ។

**ប្រការ ២៤ :** គណៈកម្មការអចិន្ត្រៃយ៏នៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ អាចបង្កើតក្រុមការងារផ្សេងៗដើម្បីជាជំនួយ ដូចជា ក្រុមការងារបណ្តាញ ក្រុមការងារពត៌មាន ឃោសនា និងផ្សព្វផ្សាយ ។ល។

**ប្រការ ២៥ :** ប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ មានភារកិច្ច និងកាតព្វកិច្ចដូចតទៅ :

- ធានាដំណើរការនៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ឲ្យស្របតាមគោលការណ៏របស់គណបក្ស
- កោះប្រជុំ និងដឹកនាំអង្គប្រជុំនៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ
- អនុវត្តផែនការដែលគណបក្សប្រគល់ជូន
- ធ្វើរបាយការណ៏ស្តីអំពីសកម្មភាពការងារគណបក្សនៅក្នុងស្រុក-ខណ្ឌ និងលើកសំណូមពរផ្សេងៗ ជូនក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង និងថ្នាក់ដឹកនាំគណបក្ស

_បញ្ជាចំណាយទៅតាមផែនការ និងតាមការចាំបាច់របស់ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ។

**ប្រការ ២៦ :** អនុប្រធាន លេខាធិការ និងហេរញ្ញិកនៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ជួយកិច្ចការប្រធាន និងទទួលភារកិច្ចតាមការកំណត់របស់ប្រធាន ។ អនុប្រធានមួយរូបដឹកនាំការងារជំនួសប្រធានតាមការប្រគល់សិទ្ធិក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ។

**ប្រការ ២៧ :** ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ត្រូវជួបប្រជុំគ្នាយ៉ាងតិចបីខែម្តង ដោយមានការចូលរួមពីប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ទាំងឡាយ នៅក្នុងស្រុក-ខណ្ឌសាមី ដើម្បីពិនិត្យ វាយតម្លៃសកម្មភាពការងារនៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ និងស្ថានការណ៍ទូទៅនៅក្នុងស្រុក-ខណ្ឌ និងកំណត់ផែនការការងារសំរាប់ពេលខាងមុខ ។ ក្នុងករណីពិសេស ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌអាចប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើមួយភាគបីនៃសមាជិករបស់ខ្លួន ។ ការប្រជុំក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ឬអនុប្រធាន តាមការប្រគល់សិទ្ធិពីប្រធាន ។

**ប្រការ ២៨ :** ក្នុងករណីសមាជិកក្រុមប្រឹក្សាគណបក្សភូមិរូបណា ត្រូវបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ហើយបានជាប់ឆ្នោតបន្តជាសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ សមាជិករូបនោះត្រូវលាលែងពីតួនាទីដើមរបស់ខ្លួននៅថ្នាក់ភូមិ និងឃុំ-សង្កាត់ ។

**ប្រការ ២៩ :** សមាជិកក្រុមប្រឹក្សាគណបក្សភូមិ ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ បាត់បង់សមាជិកភាពរបស់ខ្លួន ដោយ :

_មរណភាព

_ការសុំលាលែង

_ការផ្លាស់ទីលំនៅចេញពីភូមិ ឬឃុំ-សង្កាត់ ឬស្រុក-ខណ្ឌ

_បោះបង់ចោលការងារដោយពុំមានដំណឹងរយៈពេលលើសពីបីខែ

_ការលុបឈ្មោះចេញពីបញ្ជីសមាជិកគណបក្ស ។

ករណីនេះ ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដោយមានការយល់ព្រមពីអគ្គលេខាធិការគណបក្ស អាចរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សភូមិ សមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ជំនួសសមាជិកចាស់ ដែលបាត់បង់សមាជិកភាពរបស់ខ្លួន ។

# ជំពូក ២

## ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង

**ប្រការ ៣០ :** ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនីមួយៗ មានសមាជិកយ៉ាងតិចចំនួន ១០ រូប ។ សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបានជ្រើសតាំងឡើងដោយសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងឡាយនៅក្នុងខេត្ត-ក្រុងសាមី តាមរយៈការបោះឆ្នោតសម្ងាត់ និងដោយសម្លេងភាគច្រើនធៀប ។ រៀងរាល់រយៈពេល៣ឆ្នាំ សមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងឡាយនៅក្នុងខេត្ត-ក្រុងសាមី អាចជួបប្រជុំដើម្បីបោះឆ្នោតដកតួនាទី ឬជ្រើសតាំងបន្ថែមសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។ ចំនួនសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលត្រូវជ្រើសតាំងបន្ថែមមិនត្រូវមានចំនួនលើសពី១០ រូបឡើយ ។ សមាជិកគណបក្ស ដែលមានបំណងឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវដាក់ពាក្យសុំមកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស តាមរយៈអគ្គលេខាធិការគណបក្ស ។ ទំរង់បែបបទនៃពាក្យសុំត្រូវកំណត់ដោយអគ្គលេខាធិការគណបក្ស ។

**ប្រការ ៣១ :** សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងគ្រប់រូប មានកាតព្វកិច្ចបង់ភាគទានចូលថវិកាក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តាមការសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។ ក្នុងករណីសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបណា មិនបានបង់ភាគទានចំនួនបីខែជាប់ៗគ្នា ត្រូវបាត់បង់សមាជិកភាពដោយស្វ័យប្រវត្តិ ។

**ប្រការ ៣២ :** ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង បង្កើតគណៈកម្មការអចិន្ត្រៃយ៍ ដើម្បីដឹកនាំ ចាត់ចែង និងអនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្សខេត្ត-ក្រុង ។ គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង មាន :

- ប្រធាន
- អនុប្រធាន២រូប ដែល១រូបទទួលបន្ទុកជាប្រធានទីស្នាក់ការគណបក្សខេត្ត-ក្រុង
- លេខាធិការ
- ហេរញ្ញិក និង
- ស្នងការគណនេយ្យ ។

**ប្រការ ៣៣ :** ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌនៅក្នុងខេត្ត-ក្រុងសាមី តាមរយៈការបោះឆ្នោតដោយសម្ងាត់

ដោយសម្លេងភាគច្រើនដាច់ខាត នៃអ្នកមានសិទ្ធិបោះឆ្នោត សំរាប់អាណត្តិ៣ឆ្នាំ ។ អាណត្តិរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបញ្ចប់នៅពេលប្រធានថ្មីមកជំនួស ។

ក្នុងករណីពិសេស ប្រធានគណបក្សមានសិទ្ធិតែងតាំងជាបណ្តោះអាសន្ន ជំនួសប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបណា ដែលធ្វើសកម្មភាពជាក់ស្តែងផ្ទុយពីផលប្រយោជន៍គណបក្ស ។ ការតែងតាំងជាបណ្តោះអាសន្ននេះ មិនត្រូវមានរយៈពេលលើសពី៣ខែឡើយ ។

**ប្រការ ៣៤ :** អនុប្រធាន លេខាធិការ និងហេរញ្ញិក នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបានជ្រើសតាំងដោយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។ ស្នងការគណនេយ្យនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកទាំងអស់ ។ អាណត្តិរបស់អនុប្រធាន លេខាធិការ ហេរញ្ញិក និងស្នងការគណនេយ្យ ត្រូវចប់ជាមួយនឹងអាណត្តិរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។

**ប្រការ ៣៥ :** ប្រធាន អនុប្រធាន លេខាធិការ ហេរញ្ញិក ស្នងការគណនេយ្យ និងសមាជិកនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវទទួលស្គាល់ដោយប្រធានគណបក្ស តាមសំណើរបស់អគ្គលេខាធិការគណបក្ស ។

**ប្រការ ៣៦ :** មតិមួយភាគបីនៃចំនួន អ្នកមានសិទ្ធិបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង មានសិទ្ធិធ្វើញត្តិមកក្រុមប្រឹក្សាវិន័យ និងដោះស្រាយវិវាទរបស់គណបក្ស ដើម្បីសុំដកសេចក្តីទុកចិត្តពីប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ឬពីស្នងការគណនេយ្យនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។

ក្រុមប្រឹក្សាវិន័យ និងដោះស្រាយវិវាទ មានភារកិច្ចធ្វើការស៊ើបអង្កេតលើញត្តិនេះ ។ បើញត្តិនេះឥតមានក្លែងបន្លំ ហើយមានមូលដ្ឋាន និងមូលហេតុច្បាស់លាស់ ក្រុមប្រឹក្សាវិន័យ និងដោះស្រាយវិវាទ ស្នើទៅគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ឲ្យរៀបចំការបោះឆ្នោតសំដែងការទុកចិត្ត ចំពោះប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ឬស្នងការគណនេយ្យនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តាមនីតិវិធីដែលបានកំណត់នៅក្នុងបទបញ្ជានេះ ។

**ប្រការ ៣៧ :** ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង មានតួនាទី និងភារកិច្ច ដូចតទៅ :

- អនុវត្តទិសដៅ និងភារកិច្ចដែលគណបក្សប្រគល់ជូន
- ធានាការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ឲ្យមានប្រសិទ្ធភាព

_រៀបចំផែនការរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងសំរាប់ខេត្ត-ក្រុងសាមី

_ស្វែងរកថវិកាតាមវិធីស្របច្បាប់ បន្ថែមពីលើថវិកាដែលសមាជិកម្នាក់ៗបានបង់ ដើម្បីទ្រទ្រង់ និងធានាសកម្មភាពរបស់គណបក្សខេត្ត-ក្រុងនីមួយៗឱ្យដំណើរការល្អប្រសើរ

_ពង្រីក និងពង្រឹងបណ្តាញ និងរចនាសម្ព័ន្ធគណបក្សពីថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ រហូតដល់ភូមិឱ្យកាន់តែរឹងមាំ

_សិក្សា និងស្វែងយល់អំពីសកម្មភាព និងបុគ្គលិកលក្ខណៈរបស់សកម្មជនតាមខេត្ត-ក្រុង និងស្វែងរកបេក្ខជនមេឃុំ-ចៅសង្កាត់ ដែលមានលក្ខណៈសម្បត្តិស្របតាមឆន្ទៈប្រជារាស្ត្រមូលដ្ឋាន

_សិក្សា ស្រាវជ្រាវ អំពីលក្ខណៈនៃការបោះឆ្នោតមុនៗ ដើម្បីជាបទពិសោធន៍សំរាប់ការបោះឆ្នោតលើកក្រោយ

_រៀបចំសមាជគណបក្សខេត្ត តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

_ចូលរួមបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រ ក្នុងមណ្ឌលខេត្ត-ក្រុងសាមី តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

**ប្រការ ៣៨ :** គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវមានទីស្នាក់ការរបស់ខ្លួន ដែលជាទីស្នាក់ការគណបក្សខេត្ត-ក្រុង ហើយមានការិយាល័យរដ្ឋបាល និងបណ្តាញ ការិយាល័យទំនាក់ទំនងសាធារណៈ និងការិយាល័យសេវាកម្ម ដើម្បីសម្រួលដល់ដំណើរការគណបក្សខេត្ត-ក្រុង ។ ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ដែលតែងតាំងដោយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។

**ប្រការ ៣៩ :** គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង មានភារកិច្ចដូចតទៅ :

_ដឹកនាំ និងត្រួតពិនិត្យការងារប្រចាំថ្ងៃនៃគណបក្សខេត្ត-ក្រុង

_ដោះស្រាយការងារគណបក្សប្រចាំថ្ងៃនៅក្នុងខេត្ត-ក្រុង

_លើកគម្រោងថវិការបស់គណបក្សខេត្ត-ក្រុងសាមី ដាក់ជូនក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងអនុម័ត

_ជួយជាមតិក្នុងការគ្រប់គ្រង និងដឹកនាំការងារប្រចាំថ្ងៃ ដល់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង

_ជួយរៀបចំ និងទ្រទ្រង់ដំណើរការនៃចលនាយុវជនជាតិខ្មែរ និងចលនានារីជាតិខ្មែរនៅក្នុងខេត្ត-ក្រុងសាមី ។

**ប្រការ ៤០ :** ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង មានភារកិច្ចដូចតទៅ :

- ធានាដំណើរការនៃទីស្នាក់ការគណបក្សខេត្ត-ក្រុង
- ធានាការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ឲ្យស្របតាមលិខិតបទដ្ឋាននានារបស់គណបក្ស
- គ្រប់គ្រង និងដឹកនាំការងារប្រចាំថ្ងៃរបស់គណបក្សខេត្ត-ក្រុង
- អនុវត្តផែនការការងារដែលក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងបានកំណត់
- រៀបចំរបាយការណ៍ប្រចាំខែ រួមទាំងចំណូល-ចំណាយថវិកា និងលើកសំណូមពរផ្សេងៗ ជូនអគ្គលេខាធិការគណបក្ស
- បញ្ជាចំណាយតាមការសំរេចរបស់ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។

**ប្រការ ៤១ :** អនុប្រធាន លេខាធិការ និងហេរញ្ញិក នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ជួយកិច្ចការប្រធាន និងទទួលភារកិច្ច តាមការកំណត់របស់ប្រធាន ។ អនុប្រធានមួយរូប អាចដឹកនាំការងារជំនួសប្រធានបានតាមការប្រគល់សិទ្ធិ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ។

**ប្រការ ៤២ :** ស្នងការគណនេយ្យមានភារកិច្ច :

- ត្រួតពិនិត្យលើរាល់បញ្ជីចំណូល-ចំណាយនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង
- វាយតម្លៃចំពោះរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ហើយរាយការណ៍ជូនក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ។

**ប្រការ ៤៣ :** ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ពិភាក្សាជាមួយអគ្គលេខាធិការគណបក្ស បង្កើតក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌ ឬឃុំ-សង្កាត់ ។ មតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ឬឃុំ-សង្កាត់ មានសិទ្ធិសុំផ្លាស់ប្តូរក្រុមទ្រទ្រង់ការងារគណបក្សដែលប្រចាំនៅស្រុក-ខណ្ឌ ឬឃុំ-សង្កាត់របស់ខ្លួន ។ តួនាទី និងភារកិច្ចរបស់ក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌ ឬឃុំ-សង្កាត់ កំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

**ប្រការ ៤៤ :** ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវជួបប្រជុំគ្នាយ៉ាងតិច ៣ ខែម្តង ដើម្បីពិនិត្យវាយតម្លៃសកម្មភាពការងារនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង និងស្ថានការណ៍ទូទៅនៅក្នុងខេត្ត-ក្រុង និងកំណត់ផែនការការងារសំរាប់ពេលខាងមុខ ។ ក្នុងករណីពិសេស ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងអាចប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើមួយភាគបីនៃសមាជិករបស់ខ្លួន ។ ការប្រជុំក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ឬអនុប្រធាន តាមការប្រគល់សិទ្ធិពីប្រធាន ។

## ជំពូក ៣
## កូរ៉ុម និងនីតិវិធីនៃការបោះឆ្នោត

**ប្រការ ៤៥ :** ដើម្បីឲ្យអង្គប្រជុំធ្វើសេចក្ដីសំរេចយកជាការបាន ការប្រជុំក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ឬស្រុក-ខណ្ឌ ឬខេត្ត-ក្រុង ចាំបាច់ត្រូវមានកូរ៉ុម៦ភាគ១០ នៃចំនួនសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ទាំងអស់ ឬសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងអស់ ឬសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងទាំងអស់ ។ សេចក្ដីសំរេចដែលអាចយកជាការបាន លុះត្រាតែទទួលបានសម្លេងគាំទ្រ៥០ភាគរយបូក១ នៃចំនួនសមាជិកក្រុមប្រឹក្សាគណបក្សថ្នាក់នីមួយៗ (ឃុំ-សង្កាត់ ស្រុក-ខណ្ឌ ខេត្ត-ក្រុង) ។

**ប្រការ ៤៦ :** គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានតួនាទីណែនាំអំពីនីតិវិធី និងបែបបទនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សភូមិ ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ និងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។

## ជំពូក ៤
## អវសានបញ្ញត្តិ

**ប្រការ ៤៧ :** បទបញ្ញានេះអាចកែសម្រួលបានទៅតាមការចាំបាច់របស់គណបក្ស តាមសំណើរបស់ប្រធានគណបក្ស ឬមតិមួយភាគបីនៃសមាជិកគណៈកម្មាធិការនាយកគណបក្ស ។

**ប្រការ ៤៨ :** បទបញ្ញានេះ ត្រូវបានកែសំរួលឡើងវិញ ហើយអនុម័តដោយគណៈកម្មាធិការនាយកគណបក្សនៅក្នុងកិច្ចប្រជុំថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ ។

**ប្រការ ៤៩ :** ទុកជានិរាករណ៍ នូវរាល់បទបញ្ញាទាំងឡាយណា ដែលផ្ទុយពីបទបញ្ញានេះ ។

**ប្រការ ៥០ :** បទបញ្ញានេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦*

ប្រធានគណបក្ស

សម រង្ស៊ី